# ព្រឹត្តិបត្រប្រចាំត្រីមាសទី២

## គាំទ្រសមាគម គឺពង្រឹងវិស័យទឹកស្អាតនៅកម្ពុជា

សម្រាប់ ខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៦

## ១. បច្ចុប្បន្នភាពអំពីសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយមានស្ថាបនិកចំនួន ២០ រូប និងត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីសមាគមតាមរយៈលិខិតលេខ ១០៧៧ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។

ដោយមានភាពរីកចម្រើន ទទួលបានទំនុកចិត្ត និងការគាំទ្រពីប្រតិបត្តិករ ក្រុមហ៊ុន សហគ្រាស និងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា សមាគមបានសម្រេចបញ្ចូលសមាជិកបន្ថែមមានទាំងរូបវន្តបុគ្គល និងនិតិបុគ្គល។ ដូច្នេះហើយទើបក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសលេខ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋានទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៦ សមាគមមានសមាជិកសរុបចំនួន ៣៣៨ ក្នុងនោះមានសមាជិកអាជីពចំនួន ២៨៥ ស្ថានីយ ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣ រាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា និងសមាជិកគាំទ្រចំនួន ៥៣ ក្រុមហ៊ុន។

## ១.១. បច្ចុប្បន្នភាពសមាជិក

តារាងបច្ចុប្បន្នភាពសមាជិកគិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៦៖




## ១.២. បច្ចុប្បន្នភាពអំពីសមាជិកសមាគម

តារាងបច្ចុប្បន្នភាពអំពីសមាជិកគិតត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៦៖

| ចំនួនសមាជិក | សមាជិកអាជីព | សមាជិកគាំទ្រ | សរុប |
|---|---|---|---|
| ចំនួនសមាជិកសរុបត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២៦ | ២៨១ | ៥១ | ៣៣២ |
| ចំនួនសមាជិកថ្មី | ៤ | ២ | ៦ |
| ចំនួនសមាជិកសរុបត្រឹមត្រីមាសទី២ ឆ្នាំ២០២៦ | ២៨៥ | ៥៣ | ៣៣៨ |

# ២. ការខារស្នូលសមាគម

## ២.១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី២ នេះសមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបានចំនួន ៣លើក ដូចខាងក្រោម៖

❖ លើកទី១ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសទី១ នៅការិយាល័យសមាគម និងតាមប្រព័ន្ធ Online (Zoom Call)។ កិច្ចប្រជុំនេះមានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម។

គោលបំណងនៃកិច្ចប្រជុំ៖

១. ពិនិត្យ និងចុះហត្ថលេខាលើ«កំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រីមាសទី៤ ឆ្នាំ២០២៥ និងឆ្លុះបញ្ចាំងការងារឆ្នាំ២០២៥ និងលើកផែនការឆ្នាំ២០២៦»

២. លទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០២៦ និងផែនការត្រីមាសទី២ ឆ្នាំ២០២៦

៣. ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់លើកទី១ នៅខេត្តសៀមរាបដែលប្រព្រឹត្តទៅនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦

❖ លើកទី២ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលនៅការិយាល័យសមាគម និងតាមប្រព័ន្ធអនឡាញ (Zoom Call)។ សមាសភាពអ្នកចូលរួមមាន៖ ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រងសមាគម។ កិច្ចប្រជុំផ្តោតលើបច្ចុប្បន្នភាពប្រាក់សមាជិកភាពប្រចាំឆ្នាំ។ ជាលទ្ធផល ក្រុមប្រឹក្សាភិបាលបានអនុម័តធ្វើបច្ចុប្បន្នភាពប្រាក់សមាជិកភាពប្រចាំឆ្នាំថ្មីដើម្បីឱ្យស្របតាមស្ថានភាពបច្ចុប្បន្ន។ ប្រាក់សមាជិកភាពថ្មីនេះ នឹងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ ខាងមុខ។



*រូបភាពទី 1៖ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល*




❖ លើកទី៣ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលតាមប្រព័ន្ធអនឡាញ (Zoom Call)។ សមាសភាពអ្នកចូលរួមមាន៖ ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រងសមាគម។ កិច្ចប្រជុំមានរបៀបវារៈដូចខាងក្រោម៖

១. ករណីស្ថានីយទឹកស្អាតសំបួរមាស៖ ការជួបពិភាក្សាជាមួយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការតបណ្តាញទឹកស្អាតចូល

បុរីឡេងណាវ៉ា

២. ករណីស្ថានីយទឹកស្អាតសូទ្រនិគម៖ អំពីការខូចខាតបណ្តាញបំពង់ទឹកស្អាត ព្រោះតែការសាងសង់ផ្លូវ

៣. ការតែងតាំងនាយកប្រតិបត្តិស្តីទី ក្នុងកំឡុងពេល លោកនាយកប្រតិបត្តិឈប់សម្រាកប្រចាំឆ្នាំ



សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ផ.ក)
Cambodian Water Supply Association (C.W.A)

លេខ៖ ០៩៦/២០២៦ ស.ផ.ក

**លិខិតចាត់តាំង**
**លោក ផង់ ចិន្តា និង លោកស្រី ស៊ឹម បូនិច**
ជានាយកប្រតិបត្តិស្តីទី សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

- យោងតាមលក្ខន្តិកៈរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- លិខិតអនុញ្ញាតច្បាប់របស់ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម ពីថ្ងៃទី២៣ ខែមិថុនា រហូតដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦

**លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា សូមចាត់តាំង៖

1. **លោក ផង់ ចិន្តា** ប្រធានផ្នែកសមាជិក និងដៃគូ នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជានាយកប្រតិបត្តិស្តីទី ចាប់ពីថ្ងៃទី២៣-២៨ ខែមិថុនា ឆ្នាំ២០២៦។
2. **លោកស្រី ស៊ឹម បូនិច** ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជានាយកប្រតិបត្តិស្តីទី ចាប់ពីថ្ងៃទី២៩ ខែមិថុនា រហូតដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា មេត្តាផ្តល់កិច្ចសហការក្នុងក្របខណ្ឌសមាគមដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦
ប្រធានក្រុមប្រឹក្សាភិបាល

**ឡេង ខៀវ**

**ចម្លងជូន**
- *ក្រុមប្រឹក្សាភិបាល សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*
- *ឯកសារ កាលប្បវត្តិ*

**ភ្ជាប់ជូន**
- *លិខិតអនុញ្ញាតច្បាប់របស់ លោក លឹម មិញ*

## ២.២. កិច្ចប្រជុំថ្នាក់តំបន់

នៅក្នុងត្រីមាសទី២ នេះសមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ១ លើក នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ នៅសណ្ឋាគារ អង្គរប៉ារ៉ាឌី ខេត្តសៀមរាប ក្នុងគោលបំណង៖

១. ស្តាប់សំឡេងរបស់សមាជិក និងរួមគ្នាស្វែងរកដំណោះស្រាយ

២. បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ សមាជិកសមាគម និងដៃគូអភិវឌ្ឍន៍នានា

៣. ធ្វើបច្ចុប្បន្នភាពអំពីសមាគម ច្បាប់គតិយុត្តនានាទាក់ទងទៅនឹងវិស័យទឹកស្អាត ដំណោះស្រាយហិរញ្ញវត្ថុ ការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។



*រូបភាពទី 2៖ គណៈអធិបតី កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប*

កិច្ចប្រជុំទទួលបានអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លោកជំទាវ **ម៉ននី រង្សី** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប និងលោក **សៀ សេងហ៊ាប** ហេរញ្ញិក ជាតំណាងដ៏ខ្ពស់ខ្ពស់ក្រុមប្រឹក្សាភិបាលសមាគម។

កិច្ចប្រជុំមានការអញ្ជើញចូលរួមពីក្រសួង ឧ.វ.ប.ន. រដ្ឋបាលខេត្ត សៀមរាប កំពង់ធំ និងខេត្តបន្ទាយមានជ័យ មន្ទីរ ឧ.វ.ប.ន. ខេត្តសៀមរាប កំពង់ធំ បន្ទាយមានជ័យ ព្រះវិហារ និងខេត្តឧត្តរមានជ័យ មន្ទីរអភិវឌ្ឍន៍ជន មន្ទីរធនធានទឹក និងឧតុនិយម មន្ទីររ៉ែ និងថាមពល មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនមកពីខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ ព្រះវិហារ បាត់ដំបង តាកែវ និងខេត្តកណ្តាល តំណាងអង្គការ Water.org សមាគម និងតំណាងក្រុមហ៊ុនដែលបានចូលរួមឧបត្ថម្ភដល់កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប សរុបចំនួន ១១៥ នាក់ (ស្រី ២០នាក់) ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៤១ នាក់ (ស្រី ១០ នាក់) ដែលអញ្ជើញមកពី ៣៦ ស្ថានីយ។



*រូបភាពទី 3៖ កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប*



*រូបភាពទី 4៖ ការទស្សនាស្តង់បង្ហាញផលិតផលរបស់គណៈអធិបតី*

## ២.៣. កិច្ចគាំពារសមាជិក

ក្នុងត្រីមាសទី២ នេះសមាគមបានជួយសម្របសម្រួលដោះស្រាយបញ្ហា និងគាំទ្រសមាជិកដូចជាការសម្របសម្រួលទាំងនោះរួមមាន ការជួយរៀបចំលិខិតរដ្ឋបាល បណ្ដឹង ការរៀបចំពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត វេទិកាសាធារណៈ ការសម្រុះសម្រួលវិវាទ។ សមាជិកទាំងនោះរួមមាន៖

| ល.រ | ឈ្មោះស្ថានីយ | ខេត្ត |
|---|---|---|
| ១ | ស្ថានីយទឹកស្អាត ពោធិបាន | កណ្ដាល |
| ២ | ស្ថានីយទឹកស្អាត ឃុំត្រើយស្លា | កណ្ដាល |
| ៣ | ស្ថានីយទឹកស្អាត ថ្នល់បំបែកសន្លុង | តាកែវ |
| ៤ | ស្ថានីយទឹកស្អាត ឈើទាលភ្លោះ | តាកែវ |
| ៥ | ស្ថានីយទឹកស្អាត ព្រែកតាមាក់ | កណ្ដាល |
| ៦ | ស្ថានីយទឹកស្អាត សូទ្រនិគម | សៀមរាប |
| ៧ | ស្ថានីយទឹកស្អាត សំបួរមាស | កណ្ដាល |
| ៨ | ស្ថានីយទឹកស្អាត ម៉ារីនពេជ្រសារ | កណ្ដាល |
| ៩ | ស្ថានីយទឹកស្អាត សុត សឿន | ពោធិ៍សាត់ |
| ១០ | ស្ថានីយទឹកស្អាត លំពង់ | តាកែវ |
| ១១ | ស្ថានីយទឹកស្អាត ហ្វ្រីនហ្សួន | បន្ទាយមានជ័យ |

## ២.៤. ការចុះសួរសុខទុក្ខសមាជិក

ក្នុងត្រីមាសទី២ សមាគមបានចុះសួរសុខទុក្ខសមាជិករបស់ខ្លួនដែលជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៩ ស្ថានីយ ក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនង ស្វែងយល់អំពីស្ថានភាពទូទៅរបស់សមាជិក បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយសមស្របជូនសមាជិក ព្រមទាំងផ្តល់អនុសាសន៍ណែនាំដល់សមាជិកក្នុងការកែលម្អ។

តារាងស្ថានីយដែលសមាគមបានចុះសួរសុខទុក្ខ៖

| ល.រ | ឈ្មោះស្ថានីយ | ខេត្ត |
|---|---|---|
| ១ | ស្ថានីយទឹកស្អាត ម៉ារីនពេជសារ | តាកែវ |
| ២ | ស្ថានីយទឹកស្អាត ក្រពុំឈូក | តាកែវ |
| ៣ | ស្ថានីយទឹកស្អាត ឈើទាលភ្លោះ | តាកែវ |
| ៤ | ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត | បាត់ដំបង |
| ៥ | ស្ថានីយទឹកស្អាត បាណន់ | បាត់ដំបង |
| ៦ | ស្ថានីយទឹកស្អាត អូរតាគន់ | បាត់ដំបង |
| ៧ | ស្ថានីយទឹកស្អាត ជីក្រែង | សៀមរាប |
| ៨ | ស្ថានីយទឹកស្អាត កំពង់ថ្ម | កំពង់ធំ |
| ៩ | ស្ថានីយទឹកស្អាត ថ្មគោល | បាត់ដំបង |




*រូបភាពទី 5៖ ការចុះសួរសុខទុក្ខសមាជិក*







*រូបភាពទី 6៖ សកម្មភាពចុះសួរសុខទុក្ខសមាជិកតាមបណ្ដាខេត្តនានា*




## ២.៤. ការធ្វើតេស្តគុណភាពទឹកស្អាត និងជ្យារតេស្ត

នៅក្នុងត្រីមាសទី២ នេះបុគ្គលិកបច្ចេកទេសសមាគមបានការធ្វើតេស្តគុណភាពទឹកស្អាត និងធ្វើជ្យារតេស្តជូនសមាជិកដូចខាងក្រោម៖

| ល.រ | ការតេស្តគុណភាពទឹកស្អាត |
|---|---|
| ១ | ស្ថានីយទឹកស្អាត ស្រុកភ្នំព្រឹក |
| ២ | ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត |
| ៣ | ស្ថានីយទឹកស្អាត រតនៈមង្គល |
| | **ការធ្វើជ្យារតេស្ត** |
| ១ | ស្ថានីយទឹកស្អាត ស្រុកភ្នំព្រឹក |



*រូបភាពទី 7៖ ការធ្វើតេស្តគុណភាពទឹកជូនសមាជិក*

## ២.៥. វគ្គបណ្ដុះបណ្ដាល

នៅក្នុងត្រីមាសទី២ នេះសមាគមបានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន ៣លើកៈ

❖ វគ្គបណ្ដុះបណ្ដាលស្ដីពី «ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០» ចំនួន ២វគ្គ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ។

១. ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ មានអ្នកចូលរួមសរុបចំនួន ២៧នាក់ (ស្រី ៨នាក់ )ក្នុងនោះមានប្រតិបត្តិករ អញ្ជើញមកពី ២៣ស្ថានីយ។

២. ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦ មានអ្នកចូលរួមសរុបចំនួន ៤៥នាក់ (ស្រី ៩នាក់ )ក្នុងនោះប្រតិបត្តិករ អញ្ជើញមកពី ៣៦ស្ថានីយ។



*រូបភាពទី ៨៖ វគ្គបណ្ដុះបណ្ដាលស្ដីពី ការរៀបចំផែនការវិនិយោគរយៈពេលមធ្យម*



*រូបភាពទី ៩៖ ការចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្ដីពី ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០*

❖ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៦ សមាគមបានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី «វិធីសាស្ត្រធ្វើជ្បរតេស្ត និងការវិភាគគុណភាពទឹកស្អាត» នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ វគ្គបណ្ដុះបណ្ដាលមានអ្នកចូលរួមសរុប ១៩ នាក់ (ស្រី ៦ នាក់) ព្រមទាំងប្រតិបត្តិករអញ្ជើញមកពី ១៥ ស្ថានីយ និង ២ ក្រុមហ៊ុន។



*រូបភាពទី 10៖ វគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រធ្វើផ្សារតេស្ត និងការវិភាគគុណភាពទឹកស្អាត*

## ២.៦. ការសម្របសម្រួលកិច្ចប្រជុំឃុំ

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ សមាគមបានជ្រោមជ្រែង និងគាំទ្រដល់ក្រុមហ៊ុន យុន អភិវឌ្ឍន៍ ក្នុងការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយឃុំ/សង្កាត់ ក្រោមអធិបតី ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **តន់ សុខជា** អគ្គនាយក នៃអគ្គនាយកដ្ឋានទឹកស្អាត និងជាតំណាងដ៏ខ្ពស់ខ្ពស់របស់ ក្រសួង ឧ.វ.ប.ន. ជាប្រធានគណៈអធិបតី ព្រមទាំងវត្តមានពីភ្ញៀវកិត្តិយសរួមមាន៖ ១).ប្រតិភូនៃក្រសួង ឧ.វ.ប.ន. ២).មន្ទីរពាក់ព័ន្ធ ៣).រដ្ឋបាលក្រុងសិរីសោភ័ណ ៤).រដ្ឋបាលឃុំ/សង្កាត់ ៥). ថ្នាក់ដឹកនាំ និងបុគ្គលិកក្រុមហ៊ុន យុន អភិវឌ្ឍន៍ ៦).តំណាងមណ្ឌលសុខភាព ៧).តំណាងសាលារៀន ៨).តំណាងសហគមន៍ និង ៩).ប្រតិបត្តករផ្គត់ផ្គង់ទឹកស្អាតឯកជន។

ប្រជុំនេះមានគោលបំណងសំខាន់ចំនួន ៤ រួមមាន៖

១. បង្ហាញអំពីវឌ្ឍនភាពនៃអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងផែនការអភិវឌ្ឍន៍របស់ក្រុមហ៊ុន។

២. ពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ។

៣. ថ្លែងអំណរគុណចំពោះការគាំទ្ររបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអតិថិជន។

៤. ផ្តល់ព័ត៌មាន និងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមប្រព័ន្ធបំពង់។



*រូបភាពទី 11៖ កិច្ចប្រជុំប្រចាំឆ្នាំជាមួយឃុំ សង្កាត់ របស់ក្រុមហ៊ុន យុន អភិវឌ្ឍន៍*



*រូបភាពទី 12៖ ទស្សនកិច្ចសិក្សាទៅកាន់ ក្រុមហ៊ុន យុន អភិវឌ្ឍន៍*

## ២.៧. កិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត

នៅក្នុងត្រីមាសទី២ នេះសមាគមបានរៀបចំកិច្ចសន្ទនាប្រចាំខែអំពី វិស័យទឹកស្អាតបានចំនួន ៣ លើក តាមប្រពន្ធ័អនឡាញ និងផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុករបស់សមាគម។ កិច្ចសន្ទនាប្រចាំរួមមាន៖










## ២.៨. សន្និសីទ និងពិព័រណ៍ទឹកអាស៊ី ប្រទេសម៉ាឡេស៊ី

ថ្ងៃទី៦-១០ ខែមេសា ឆ្នាំ២០២៦ សមាគមបានដឹកនាំសមាជិកចំនួន ២៤នាក់ ចូលរួមសន្និសីទ និងពិព័រណ៍ទឹកអាស៊ី នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។ កំឡុងពេលនោះដែរសមាគមក៏បានដឹកនាំសមាជិកដើម្បីទស្សនាការដាក់បង្ហាញផលិតផលនានា អំពីវិស័យទឹកស្អាត នៅក្នុងសន្និសីទ និងពិព័រណ៍ទឹកអាស៊ី ២០២៦ ផងដែរ។



*រូបភាពទី 13៖ ប្រតិភូសមាគមចូលរួមសន្និសីទ និងពិព័រណ៍ទឹកអាស៊ី នៅប្រទេសម៉ាឡេស៊ី*





*រូបភាពទី 14៖ ប្រតិភូសមាគមចូលរួមទស្សនាពិព័រណ៍ទឹក អាស៊ី នៅប្រទេសម៉ាឡេស៊ី*

## ២.៩. សន្និសីទ និងពិព័រណ៍ទឹក OZWATER 2026 នៅទីក្រុង Brisbane

ថ្ងៃទី២៣-៣០ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការឧបត្ថម្ភគាំទ្រពីដៃគូទឹកអូស្ត្រាលី តាមរយៈសមាគមទឹកអូស្ត្រាលី(AWA) លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម បានដឹកនាំសមាជិកជាប្រតិបត្តិករផ្គង់ផ្គង់ទឹកស្អាត ចំនួន ៣ នាក់ រួមមាន លោក **William Puyo** (KWSH) លោកស្រី **ព្រាប បុទុមសិលា** អ្នកគ្រប់គ្រងស្ថានីយទឹកស្អាតសំពោងយ៉ោង លោកស្រី **មាជ ស៊ូទាង** អ្នកគ្រប់គ្រងស្ថានីយទឹកស្អាត ត្បែងខ្ពស់ ចូលរួមក្នុងព្រឹត្តិការណ៍ OZWATER 2026 នៅទីក្រុង Brisbane ប្រទេសអូស្ត្រាលី។

ក្នុងសន្និសីទ និងពិព័រណ៍ រួមមាន សកម្មភាពបង្កើតបណ្តាញទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចប្រជុំដើម្បីពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រ។ លើសពីនេះទៀត លោកនាយក បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាជាក្រុមស្តីពី ការចូលរួមរបស់សាធារណជនក្នុងវិស័យទឹកស្អាតផងដែរ។





*រូបភាពទី 15៖ ប្រតិភូសមាគមចូលរួម OZWATER' 2026 នៅប្រទេសអូស្ត្រាលី*

ក្នុងកិច្ចពិភាក្សា លោកនាយកប្រតិបត្តិ បានចែករំលែកបទពិសោធន៍ជាក់ស្តែង និងឧទាហរណ៍ពីការអនុវត្តក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតរបស់ប្រទេសកម្ពុជាដោយបានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗ មេរៀនដែលទទួលបាន និងវិធីសាស្ត្រជោគជ័យក្នុងការចូលរួមជាមួយសហគមន៍។ លោកបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់សាធារណជន កិច្ចសហការជាមួយភាគីពាក់ព័ន្ធ និងការចូលរួមរបស់អតិថិជនក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃអង្គភាពផ្គត់ផ្គង់ទឹក និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យនេះ។



*រូបភាពទី 16៖ លោកនាយកប្រតិបត្តិសមាគម ចូលរួមចែករំលែកបទពិសោធន៍ក្នុងកិច្ចពិភាក្សា*

## ៣.៥. ការជួបសម្តែងការគួរសម

នៅក្នុងត្រីមាសទី២ នេះសមាគមបានចូលជួបសម្តែងការគួរសម ចំនួន ២ លើក៖

- លើកទី១ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ ថ្នាក់ដឹកនាំសមាគម និងសហការីបានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តសៀមរាប ដែលដឹកនាំដោយ លោក **ឌី រ៉ាជូ** អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប និងមានការចូលរួមពីលោកប្រធាន អនុប្រធាន និងមន្ត្រីមន្ទីរពាក់ព័ន្ធរួមមាន៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីររ៉ែ និងថាមពល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីបង្ហាញពីការងាររបស់សមាគម ការផ្គត់ផ្គង់ទឹកស្អាត និងបញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ជាពិសេសប្រតិបត្តិករក្នុងខេត្តសៀមរាប ក្នុងគោលបំណងទទួលបានការគាំទ្រពីរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ។



*រូបភាពទី 17៖ ការជួបសម្តែងការគួរសមជាមួយរដ្ឋបាលខេត្តសៀមរាប*

❖ លើកទី២ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៦ ថ្នាក់ដឹកនាំសមាគមបានចូលជួបសម្តែងការគួរសមជាមួយ លោកស្រី **ស៊ឹម ណារី** ប្រធានមន្ទីរ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពត។

កិច្ចប្រជុំនេះផ្តោតលើសារៈប្រយោជន៍នៃការចូលជាសមាជិកសមាគម និងស្នើសុំឱ្យមន្ទីរជួយសម្របសម្រួលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងខេត្តកំពតឱ្យចូលជាសមាជិកសមាគម និងការកសាងទំនាក់ទំនងរវាងមន្ទីរ និងសមាគម។



*រូបភាពទី 18៖ ការជួបសំណេះសំណាលជាមួយមន្ទីរ ឧ.វ.ប.ន. ខេត្តកំពត*

# ៣. ការងារគម្រោង

## ៣.១ គម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមចំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

### ៣.១.១ ការជ្រើសរើសសមាជិកគម្រោងបន្ថែម

ក្នុងត្រីមាសទី២ ឆ្នាំ២០២៦ នេះ គម្រោងបានជ្រើសរើសសមាជិកបន្ថែមចំនួន ១០ ស្ថានីយ។ សមាជិកគម្រោងសរុបគឺ ៧៤ ស្ថានីយ។

| ល.រ | ឈ្មោះស្ថានីយ | ឈ្មោះប្រតិបត្តិករ | ទីតាំង |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អៀង ម៉ាប់ | លោក អៀង ម៉ាប់ | ខេត្តកំពង់ស្ពឺ |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វាលពង់ | លោកស្រី ផែម ស៊ីណា | ខេត្តកំពង់ស្ពឺ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្អមសំណរ | លោកស្រី ទុន លក្ខិណា | ខេត្តកណ្តាល |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សង្កាត់កោះកណ្តាល | លោក ទូច សារេន | ខេត្តក្រចេះ |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សុត សឿន | លោក សុត សឿន | ខេត្តពោធិ៍សាត់ |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកភ្នំព្រឹក | លោក ម៉ែន ង៉ុក | ខេត្តបាត់ដំបង |
| ៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ថ្នល់បំបែកសន្លុង | លោក ឡេង សុផល | ខេត្តតាកែវ |
| ៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឈើទាលភ្លោះ | លោក ជាង ជួន | ខេត្តតាកែវ |
| ៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីនពេជសារ | លោកស្រី ស៊ឹប ចន្ធា | ខេត្តតាកែវ |
| ១០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រវ៉ាំ | លោក មួង យូឌី | ខេត្តកំពង់ធំ |

### ៣.១.២ ទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី

ក្រោមការឧបត្ថម្ភពីអង្គការ Water.org សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណងសិក្សាស្វែងយល់អំពីការគ្រប់គ្រងទឹកស្អាត បទប្បញ្ញត្តិបច្ចេកទេស និងមេរៀនបទពិសោធន៍ពីការអនុវត្តល្អក្នុងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅប្រទេសឥណ្ឌូនេស៊ី ព្រមទាំងស្វែងយល់អំពីវិធីសាស្ត្រកៀរគរមូលនិធិការវិនិយោគ និងហិរញ្ញប្បទានជួយដល់វិស័យទឹកស្អាត ជាពិសេសការពង្រឹង និងគាំទ្រប្រតិបត្តិករទឹកស្អាតឯកជន។ ដំណើរទស្សនកិច្ចសិក្សានេះមានរយៈពេល ៥ថ្ងៃ គិតចាប់ពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦។ សមាសភាពគណៈប្រតិភូពីប្រទេសកម្ពុជាសរុបចំនួន ២៥ នាក់ (ស្រី ១១ នាក់) អញ្ជើញពីក្រសួង ឧ.វ.ប.ន.៖ ៤ នាក់ (ស្រី ១ នាក់) អង្គការ Water.org៖ ២ នាក់ (ស្រី ១ នាក់) ប្រតិបត្តិករ៖ ១២ នាក់ (ស្រី ៦ នាក់) ក្រុមហ៊ុន Water Partners Cambodia (WPC)៖ ១ នាក់ (ស្រី ០ នាក់) សមាគម៖ ៥ នាក់ (ស្រី ៣ នាក់) និងអ្នកបកប្រែ៖ ១ នាក់ (ស្រី ០ នាក់) ។ ទស្សនកិច្ចសិក្សាមានសកម្មភាពសំខាន់ៗដូចខាងក្រោម៖

១. នៅទីក្រុងហ្សាការតា ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦ គណៈប្រតិភូកម្ពុជាបានចូលរួមកិច្ចប្រជុំការផ្លាស់ប្តូរបទពិសោធន៍អំពី«វិស័យទឹកស្អាតនៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី»



*រូបភាពទី 19៖ កិច្ចប្រជុំការផ្លាស់ប្តូរបទពិសោធន៍អំពី«វិស័យទឹកស្អាតនៅប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី»*

២. នៅទីក្រុង Bandung ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦ គណៈប្រតិភូកម្ពុជាបានចូលជួបសម្តែងការគួរសម និងទស្សនកិច្ចសិក្សាស្វែងយល់អំពីការគ្រប់គ្រងអាជីវកម្ម និងបច្ចេកទេសផលិតទឹកស្អាត ជាពិសេសប្រព័ន្ធ SCADA (Supervisory Control and Data Acquisition) នៅរដ្ឋាករទឹកសាធារណៈ (PDAM) នៃក្រុង Bandung។



*រូបភាពទី 20៖ ទស្សនកិច្ចសិក្សានៅរដ្ឋាករទឹកសាធារណៈ (PDAM) នៃក្រុង Bandung*

៣. នៅទីក្រុង Bandung ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦ គណៈប្រតិភូកម្ពុជា និងក្រុមការងារអង្គការ Water.org បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី។



*រូបភាពទី 21៖ កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីដំណើរទស្សនកិច្ចសិក្សា*

ទស្សនកិច្ចសិក្សានេះបានផ្តល់ឱកាសដ៏មានតម្លៃក្នុងការបង្កើនចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងអំពីការគ្រប់គ្រង និងការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត។ តាមរយៈការចូលរួមពិភាក្សា និងការទស្សនាកន្លែងអនុវត្តជាក់ស្តែង គណៈប្រតិភូបានយល់ច្បាស់បន្ថែមអំពីវិធីសាស្ត្រកែលម្អគុណភាពសេវាកម្ម ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (SCADA) និងទំនើបកម្ម ដើម្បីគ្រប់គ្រងទិន្នន័យ ព្រមទាំងការកាត់បន្ថយទឹកគ្មានចំណូល (NRW) និងការពង្រីកបណ្តាញផ្គត់ផ្គង់ទឹកឱ្យគ្របដណ្តប់កាន់តែទូលំទូលាយ។

លទ្ធផលសំខាន់ៗរួមមាន៖ ការយល់ដឹងអំពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ការអនុវត្តបច្ចេកវិទ្យាថ្មីៗ (ដូចជា SCADA) និងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អ។ លើសពីនេះ ទស្សនកិច្ចនេះបានបង្ហាញ

ពីសារៈសំខាន់នៃការចូលរួមហិរញ្ញវត្ថុពីវិស័យមិនមែនរដ្ឋ (non-public financing) និងយន្តការដូចជា Seed Grant, Matching Grant, Performance-Based Grant ដែលជួយលើកកម្ពស់ការវិនិយោគ និងការអភិវឌ្ឍសេវាទឹកស្អាត។ តម្លៃសំខាន់នៃទស្សនកិច្ចនេះ គឺការបង្កើតឱកាសសហការនាពេលអនាគត ការផ្លាស់ប្តូរបទពិសោធន៍ជាមួយដៃគូអន្តរជាតិ និងការយកចំណេះដឹងដែលទទួលបានទៅអនុវត្តក្នុងបរិបទកម្ពុជា។ ទស្សនកិច្ចនេះគឺជាជំហានសំខាន់មួយក្នុងការលើកកម្ពស់សមត្ថភាពស្ថាប័ន និងការអភិវឌ្ឍវិស័យទឹកស្អាតឱ្យមានប្រសិទ្ធភាព និងចីរភាពកាន់តែប្រសើរ។

### ៣.១.៣ ការកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ

### ក. ការគាំទ្រប្រតិបត្តិករលើផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

ក្រុមការងារសមាគមបានបន្តធ្វើការជាមួយក្រុមហ៊ុនបញ្ញី ដើម្បីចូលរួមគាំទ្រ និងតាមដានអំពីភាពរីកចម្រើននៃការប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ញី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតបានចំនួន ៩ ស្ថានីយ។

### ៣.១.៤ ការកសាងសមត្ថភាពផ្នែកបច្ចេកទេស

### ក. វគ្គបណ្តុះបណ្តាល

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦ ដោយមានការគាំទ្រពីអង្គការ Water.org តាមរយៈគម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត»សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មទឹកស្អាត និងការកាត់បន្ថយទឹកគ្មានចំណូល**» ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងមន្ត្រីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)។

វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាព លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម លោក **មាន ច័ន្ទណារិទ្ធ** ប្រធាននាយកប្រតិបត្តិសេវាហិរញ្ញវត្ថុអាជីវកម្ម ធនាគារFTB Bank លោក **ហួម ហាក់** អ្នកគ្រប់គ្រងភាពជាដៃគូ នៃអង្គការ Water.org ។ វគ្គបណ្តុះបណ្តាលមានអ្នកចូលរួមសរុប ៧៦ នាក់ (ស្រី ១៤ នាក់) ដែលអញ្ជើញមកពី តំណាងធនាគារ FTB តំណាងអង្គការ Water.org តំណាងក្រុមហ៊ុន KWSH តំណាងក្រុមហ៊ុន TEXTZONE Plus ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសមាគម ក្នុងនោះមាន ៥៥ នាក់ ជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អញ្ជើញមកពី ៤៧ ស្ថានីយ។



*រូបភាពទី 22៖ កម្មវិធីបើកវគ្គបណ្តុះបណ្តាល*



*រូបភាពទី 23៖ សកម្មភាពក្នុងវគ្គបណ្តុះបណ្តាល*

## ខ. ការចុះបង្វឹក

ក្នុងត្រីមាសនេះ បុគ្គលិកបច្ចេកទេសសមាគមបានផ្តល់ការបង្វឹកលើបច្ចេកទេសនៃការវិភាគគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ និងធ្វើជ្យារតេស្តគុណភាពទឹកឆៅ ព្រមទាំងបានសិក្សាពីស្ថានភាពប្រភពទឹករហូតដល់ស្ថានីយចែកចាយទឹកស្អាត ជូនដល់អ្នកគ្រប់គ្រង និងបុគ្គលិក ចំនួន ៩ ស្ថានីយ៖

| ល.រ | ឈ្មោះស្ថានីយ | កាលបរិច្ឆេទ | ខេត្ត |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បន្ទាយចក្រី | ២២.មេសា.២០២៦ | ព្រៃវែង |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រះស្តេច | ២៣.មេសា.២០២៦ | |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រតនមង្គល | ១៨.ឧសភា.២០២៦ | បាត់ដំបង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាណន់ | ១៩.ឧសភា.២០២៦ | |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រហាល | ២០.ឧសភា.២០២៦ | បន្ទាយមានជ័យ |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សុខភាពជនបទ | | |
| ៧ | ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត ថ្នល់ទទឹង | ៨.មិថុនា.២០២៦ | កណ្តាល |
| ៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អៀង ម៉ាប់ | ១១.មិថុនា.២០២៦ | កំពង់ស្ពឺ |
| ៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សង្កាត់រកាកណ្តាល | ២៥.មិថុនា.២០២៦ | ក្រចេះ |



*រូបភាពទី 24៖ សកម្មភាពបង្វឹកអំពីការធ្វើតេស្តទឹកស្អាត និងជ្យារតេស្ត*

## គ. ការចុះសួរសុខទុក្ខសមាជិកគម្រោង

ក្នុងត្រីមាសនេះ ក្រុមការងារសមាគម និងអង្គការ Water.org បានចុះសួរសុខទុក្ខ និងពិភាក្សាការងារគម្រោងជាមួយសមាជិកគម្រោងចំនួន ៤ ស្ថានីយ៖

| ល.រ | ឈ្មោះស្ថានីយ | កាលបរិច្ឆេទ | ខេត្ត |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជីក្រែង | ៨-ឧសភា-២០២៦ | សៀមរាប |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ថ្ម | | កំពង់ធំ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ខោ ប៊ុនហ៊ាត | ១៨-មិថុនា-២០២៦ | បាត់ដំបង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាណន់ | | |



*រូបភាពទី 25៖ ក្រុមការងារសមាគម និងអង្គការ Water.org បានចុះសួរសុខទុក្ខ និងពិភាក្សាការងារ*

## ៣.១.៥ ការគាំទ្រដល់សមាជិកគម្រោង

### ក. ការប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ៥ប៉ារ៉ាម៉ែត្រ និងការផ្ដល់អនុសាសន៍

សមាគមបានប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ រៀងរាល់ខែពីសមាជិក ៧៤ ស្ថានីយ ក្នុងនោះ ៥៦ ស្ថានីយ បានផ្ញើលទ្ធផលតេស្តមកសមាគមជាទៀងទាត់។ អ្នកបច្ចេកទេសរបស់សមាគមបានផ្ដល់ជាការណែនាំដល់ប្រតិបត្តិករក្នុងករណីលទ្ធផលមិនអនុលោមតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ។ ចំពោះស្ថានីយចំនួន

១៨ ស្ថានីយ ដែលមិនបានផ្ញើលទ្ធផលមកដោយសារមូលហេតុ ១) ទិញទឹកដុំពីប្រតិបត្តិករទឹកស្អាតជិតខាង និងពឹងផ្អែកលើប្រភពផ្គត់ផ្គង់នោះ ២) ខូចឧបករណ៍សម្រាប់ធ្វើតេស្តគុណភាពទឹកស្អាត និងកំពុងជួសជុល ៣) មិនមានឧបករណ៍ ៤) ប្រើប្រាស់ប្រព័ន្ធធ្វើតេស្តតាមអនឡាញ ប៉ុន្តែមិនអាចទាញយកលទ្ធផលតេស្តគុណភាពទឹកស្អាតពីប្រព័ន្ធបាន និង ៥) មិនបានផ្ញើលទ្ធផលតេស្តគុណភាពទឹកស្អាត ដែលតម្រូវឱ្យក្រុមការងារជំរុញ និងតាមដានបន្ថែម។

### ៣.១.៥ ការគាំទ្រដល់សមាជិកគម្រោង

### ក. ការប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ៥ប៉ារ៉ាម៉ែត្រ និងការផ្តល់អនុសាសន៍

សមាគមបានប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ រៀងរាល់ខែពីសមាជិក ៧៤ ស្ថានីយ ក្នុងនោះ ៥៦ ស្ថានីយ បានផ្ញើលទ្ធផលតេស្តមកសមាគមជាទៀងទាត់។ អ្នកបច្ចេកទេសរបស់សមាគមបានផ្តល់ជាការណែនាំដល់ប្រតិបត្តិករក្នុងករណីលទ្ធផលមិនអនុលោមតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ។

ចំពោះស្ថានីយចំនួន ១៨ ស្ថានីយ ដែលមិនបានផ្ញើលទ្ធផលមកដោយសារមូលហេតុ ១) ទិញទឹកដុំពីប្រតិបត្តិករទឹកស្អាតជិតខាង និងពឹងផ្អែកលើប្រភពផ្គត់ផ្គង់នោះ ២) ខូចឧបករណ៍សម្រាប់ធ្វើតេស្តគុណភាពទឹកស្អាត និងកំពុងជួសជុល ៣) មិនមានឧបករណ៍ ៤) ប្រើប្រាស់ប្រព័ន្ធធ្វើតេស្តតាមអនឡាញ ប៉ុន្តែមិនអាចទាញយកលទ្ធផលតេស្តគុណភាពទឹកស្អាតពីប្រព័ន្ធបាន និង ៥) មិនបានផ្ញើលទ្ធផលតេស្តគុណភាពទឹកស្អាត ដែលតម្រូវឱ្យក្រុមការងារជំរុញ និងតាមដានបន្ថែម។

### ខ. ការគាំទ្រលើការតាមដានទឹកគ្មានចំណូល

សមាគមបានប្រមូលលទ្ធផលតាមដានទឹកគ្មានចំណូលពីសមាជិកគម្រោងចំនួន ៧៤ ស្ថានីយ។ ជាលទ្ធផលបានបង្ហាញដូចខាងក្រោម៖

| ល.រ | លទ្ធផល | ខែមីនា | ខែមេសា | ខែឧសភា |
|---|---|---|---|---|
| ១ | កម្រិត ល្អ / ប្រសិទ្ធភាព (NRW < 20%) | ១២ ស្ថានីយ | ១៥ ស្ថានីយ | ១៣ ស្ថានីយ |
| ២ | កម្រិត មធ្យម / អាចទទួលយកបាន (NRW 20%–30%) | ១០ ស្ថានីយ | ១២ ស្ថានីយ | ១១ ស្ថានីយ |
| ៣ | កម្រិត ទាប / ការបាត់បង់ខ្ពស់ (NRW> 30%) | ៤ ស្ថានីយ | ១ ស្ថានីយ | ៤ ស្ថានីយ |
| **សរុប** | | **២៦ ស្ថានីយ** | **២៨ ស្ថានីយ** | **២៨ ស្ថានីយ** |

យោងតាមលទ្ធផលខាងលើ អ្នកបច្ចេកទេសរបស់សមាគមបានផ្តល់ជាការណែនាំដល់ប្រតិបត្តិករ ដើម្បីពិនិត្យមើលការគ្រប់គ្រងទឹកគ្មានចំណូលជូនសមាជិកផងដែរ ។

ចំពោះស្ថានីយចំនួន ៤៧ ស្ថានីយ ដែលមិនបានផ្ញើលទ្ធផលមកដោយសារមូលហេតុ ១) គ្មាននាឡិកាមេ ២) មិនមាននាឡិកាមេគ្រប់គ្រាន់ ៣) នាឡិកាមេខូចមិនដំណើរការ ៤) កត់ត្រាទិន្នន័យមិនត្រឹមត្រូវ និង ៥) មិនបានផ្ញើលទ្ធផលតាមដានទឹកគ្មានចំណូល ដែលតម្រូវឱ្យក្រុមការងារជំរុញ និងតាមដានបន្ថែម។

### គ. ការផ្តល់សេវាគូរផែនទីបណ្តាញ និងការរៀបចំផែនការវិនិយោគរយៈពេលមធ្យម

សមាគមបានផ្តល់សេវាកម្មជូនសមាជិក៖ សេវាកម្មនេះត្រូវបានចូលរួមបដិភាគពីអង្គការ Water.org ប្រតិបត្តិករ និងសមាគម៖

| ល.រ | សេវកម្ម | ចំនួនប្រតិបត្តិករ |
|---|---|---|
| ១ | គូរផែនទីបណ្ដាញបំពង់ទឹកស្អាត | ១ ស្ថានីយ |
| ២ | រៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០ | ១ ស្ថានីយ |
| ៣ | គូរផែនទីបណ្ដាញបំពង់ទឹកស្អាត និងផែនការវិនិយោគរយៈពេលមធ្យម សម្រាប់ឆ្នាំ២០២៦-២០៣០ | ១០ ស្ថានីយ |
| ៤ | កំពុងរៀបចំកិច្ចព្រមព្រៀងផ្ដល់សេវាទាំងពីរខាងលើ | ២ ស្ថានីយ |
| | **សរុប** | **១៤ ស្ថានីយ** |



*រូបភាពទី 26៖ បុគ្គលិកសមាគមចុះផ្ដល់សេវាកម្មជូនសមាជិក*

### ឃ. ឧបត្ថម្ភដល់សមាជិកគម្រោងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល

សមាជិកគម្រោងសរុបចំនួន ៤៧ ស្ថានីយ បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពី«**ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០**»។ ជាលទ្ធផល ៣៩ ស្ថានីយ បានរៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០។

## ៣.១.៦ ពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពប្រតិបត្តិការរបស់សមាជិកជាប្រតិបត្តិករ

ក្នុងត្រីមាសនេះ សមាគមបានសហការជាមួយក្រសួង ឧ.វ.ប.ន. ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តពោធិ៍សាត់ រដ្ឋបាលខេត្តបន្ទាយមានជ័យ សម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ និងដៃគូពាក់ព័ន្ធនានាស្ដីពី **«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** បានចំនួនពីរប្រជុំ ក្រោមការឧបត្ថម្ភពីអង្គការ Water.org។ គោលបំណងសំខាន់ៗនៃកិច្ចប្រជុំ រួមមាន៖

១. ផ្សព្វផ្សាយលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្ដីពី«**ការជំរុញលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**» ឱ្យកាន់តែមានប្រសិទ្ធភាព។

២. កំណត់បញ្ហាប្រឈមចម្បងៗ ស្វែងរកដំណោះស្រាយ និងរួមគ្នាក្នុងការធានាឱ្យមានភាពប្រសើរក្នុងការផ្ដល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ។

៣. បង្កើនទំនាក់ទំនង និងកិច្ចសហការរវាងក្រសួង មន្ទីរ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូ និងភាគីពាក់ព័ន្ធក្នុងវិស័យ ដើម្បីស្វែងរកការគាំទ្រក្នុងការឆ្លើយតបជាវិជ្ជមានទៅនឹងតម្រូវការរបស់ប្រជាជន។

៤. បង្កើនចំណេះដឹងបន្ថែមអំពីវិស័យផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។

**កិច្ចប្រជុំពិគ្រោះយោបល់៖**

❖ **ខេត្តពោធិ៍សាត់៖** ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៦ កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. ឯកឧត្តម **សួន តារា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ លោក **ងួន ប៉ោសេង** អភិបាលរង នៃគណៈអភិបាល ខេត្តពោធិ៍សាត់ លោក **ហ៊ុយ រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានទឹកស្អាត និង លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម ព្រមទាំងមានការអញ្ជើញចូលរួមដោយ ថ្នាក់ដឹកនាំ និងមន្ត្រីអមដំណើរនៃក្រសួង ឧ.វ.ប.ន. ថ្នាក់ដឹកនាំ និងមន្ត្រីអមដំណើរ នៃក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋាករទឹកពោធិ៍សាត់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៦ ស្ថានីយ បុគ្គលិកអង្គការ Water.org និងសមាគមសរុបចំនួន ៤៦ នាក់ (ស្រី ៧ នាក់)។



*រូបភាពទី 27៖ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តពោធិ៍សាត់*

❖ **ខេត្តបន្ទាយមានជ័យ៖** ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **តន់ សុខជា** អគ្គនាយក នៃអគ្គនាយកដ្ឋានទឹកស្អាត តំណាងឱ្យក្រសួង ឧ.វ.ប.ន. ឯកឧត្តម **ពឹម សំណាង** អនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ ឯកឧត្តម **សួន តារា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ លោក **កែ សួនសុភាព** អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម និង លោក **វង វ៉ាន់រិទ្ធ** អ្នកគ្រប់គ្រងភាពជាដៃគូនៃអង្គការ Water.org ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រីអមដំណើរនៃក្រសួង ឧ.វ.ប.ន. មន្ត្រីអមដំណើរនៃក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ១៦ ស្ថានីយ បុគ្គលិកអង្គការ Water.org និងសមាគមសរុបចំនួន ៧៦ នាក់ (ស្រី ១០ នាក់)។



*រូបភាពទី 28៖ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តបន្ទាយមានជ័យ*

## ៣.១.៧ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

### ក. ការសម្របសម្រួលកម្ចី

សម្របសម្រួល និងតាមដានសមាជិកចំនួន ២១ ស្ថានីយ ស្នើប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ និងការទម្លាក់កម្ចីដើម្បីអភិវឌ្ឍអាជីវកម្ម។ ជាលទ្ធផល ១០ ស្ថានីយ ទទួលបានប្រាក់កម្ចីពីធនាគារ ២.៤៤៥.០០០ ដុល្លារអាមេរិក (២៨៧.៥០០ ដុល្លារអាមេរិក ប្រើប្រាស់ដើម្បីសងត្រលប់កម្ចី និង ២.១៥៧.៥០០ ដុល្លារអាមេរិក ប្រើប្រាស់សម្រាប់អភិវឌ្ឍអាជីវកម្មទឹកស្អាត។ ស្ថានីយទាំង ១០ ខាងលើមានកំណើនតំណអតិថិជនថ្មីចំនួន ១.១៤៦ តំណ ស្មើនឹងប្រជាជនចំនួន ៥.៦១៥ នាក់ ទទួលបានសេវាទឹកស្អាតប្រើប្រាស់។

## ៣.១.៨ កិច្ចប្រជុំរបស់គម្រោង

នៅក្នុងត្រីមាសទី២ គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦៖ ក្រុមការងាររបស់សមាគមបានប្រជុំពិភាក្សាអំពីលទ្ធផលការងារគម្រោង និងរៀបចំផែនការបន្ទាប់។

២. ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៦៖ ក្រុមការងាររបស់សមាគមបានរៀបចំ

- ❖ ពេលព្រឹក៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលកំពុងប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ជី ដោយមានអ្នកចូលរួមសរុបចំនួន ១២ នាក់ (ស្រី ៦ នាក់)។ ក្នុងនោះ មានតំណាងប្រតិបត្តិករចំនួន ៧ នាក់ (ស្រី ៤ នាក់) មកពីស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៦។ កិច្ចប្រជុំនេះមានគោលបំណងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងបទពិសោធន៍នៃការប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ជី ព្រមទាំងប្រមូលមតិយោបល់ ដើម្បីកែលម្អ និងបន្តការគាំទ្រឱ្យកាន់តែមានប្រសិទ្ធភាព។
- ❖ ពេលរសៀល៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងក្រុមហ៊ុនបញ្ជី ដោយមានអ្នកចូលរួមសរុបចំនួន ៨ នាក់ (ស្រី ៤ នាក់)។ កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ ដើម្បីបន្តគាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលកំពុងប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ជីឱ្យកាន់តែមានប្រសិទ្ធភាព។




*រូបភាពទី 29៖ កិច្ចប្រជុំជាមួយអង្គការ Water.org និងក្រុមហ៊ុនបញ្ចី*

៣. ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦៖ ក្រុមការងាររបស់សមាគមបានរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៦ នៅខេត្តពោធិ៍សាត់។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៦ នាក់ (ស្រី ៣ នាក់) និងផ្តោតលើការរៀបចំកម្មវិធី ការសម្របសម្រួល និងការបែងចែកភារកិច្ចរវាងក្រុមការងារ។

៤. ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងធនាគារ FTB មានអ្នកចូលរួមសរុប ៧ នាក់ (ស្រី ២ នាក់)។ កិច្ចប្រជុំមានគោលបំណងពិភាក្សាអំពីការកសាងសមត្ថភាពជូនដល់ប្រតិបត្តិករដែលជាអតិថិជនរបស់ធនាគារ FTB។

៥. ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦៖ ក្រុមការងាររបស់សមាគមបានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយអង្គការ Water.org និងក្រុមហ៊ុនបញ្ចី ដោយមានអ្នកចូលរួមសរុបចំនួន ៦ នាក់ (ស្រី ៤ នាក់)។ កិច្ចប្រជុំនេះមានគោលបំណងរាយការណ៍អំពីវឌ្ឍនភាព និងលទ្ធផលនៃការគាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ក្នុងការអនុវត្ត និងប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ចី។

៦. ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦៖ ក្រុមការងាររបស់សមាគម និងអង្គការ Water.org បានប្រជុំពិភាក្សាអំពីលទ្ធផលការងារគម្រោង និងផែនការបន្ទាប់ ដោយមានអ្នកចូលរួមសរុបចំនួន ៤ នាក់ (ស្រី ១ នាក់)។

### ៣.១.៩ ការគាំទ្រសកម្មភាពស្នូលរបស់សមាគម

នៅក្នុងត្រីមាសទី២ គម្រោងបានគាំទ្រកិច្ចប្រជុំថ្នាក់តំបន់លើកទី១ ក្នុងឆ្នាំ២០២៦ ដែលប្រារព្ធនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ នៅសណ្ឋាគារ អង្គរប៉ារាឌី ខេត្តសៀមរាប។

## ៣.២ គម្រោងគាំទ្រដោយកម្មវិធី CAPRED

### ៣.២.១ គម្រោង«ការលើកកម្ពស់អ្នកអាជីពវ័យក្មេងសម្រាប់សេវាកម្មទឹកស្អាតដែលមានភាពធន់»

- រយៈពេលអនុវត្តគម្រោង៖ ចាប់ពីខែមិថុនា ឆ្នាំ២០២៦ ដល់ ខែមិថុនា ឆ្នាំ២០២៧
- ក្រុមគោលដៅ៖ វិស្វករវ័យក្មេងចំនួន ១៥ នាក់ និងប្រតិបត្តិករ ១៥ ស្ថានីយ/ក្រុមហ៊ុន
- បុគ្គលិកគម្រោង៖ នឹងជ្រើសរើសបុគ្គលិកបន្ថែមចំនួន ២ នាក់
- ស្ថានភាព៖ សមាគមបានចុះកិច្ចព្រមព្រៀងជាមួយកម្មវិធី CAPRED នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦។

### ៣.២.២ គម្រោង«ការពិភាក្សាអំពីគោលនយោបាយនៅថ្នាក់ខេត្ត ដើម្បីទទួលបានលទ្ធផល»

- រយៈពេលអនុវត្តគម្រោង៖ ចាប់ពីខែមិថុនា ឆ្នាំ២០២៦ ដល់ ខែមិថុនា ឆ្នាំ២០២៧
- ខេត្តគោលដៅ៖ ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ
- បុគ្គលិកគម្រោង៖ នឹងជ្រើសរើសបុគ្គលិកបន្ថែមចំនួន ២ នាក់
- ស្ថានភាព៖ សមាគមបានចុះកិច្ចព្រមព្រៀងជាមួយកម្មវិធី CAPRED នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦។